**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: [illegible] អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកំណត់កាលបរិច្ឆេទ នៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍

************

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍របប សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០០២ ស្តីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍តាមអាយុតាមប្រព័ន្ធព័ត៌មានវិទ្យា
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០០២ ស្តីពីការកែសម្រួលការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធបៀវត្សថ្មី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់កាលបរិច្ឆេទ នៃការដាក់ចូលនិវត្តន៍ និងការរៀបចំសោធននិវត្តន៍ ចំពោះមន្ត្រីរាជការទាំងឡាយណា ពុំទាន់បានដាក់ឱ្យចូលនិវត្តន៍ ឬយឺតយូរក្នុងការរៀបចំបែបបទដាក់ឱ្យចូលនិវត្តន៍ ។

www.pheakdeylaw.com

**មាត្រា ២ .-**

មន្ត្រីរាជការមុខងារសាធារណៈ ឬមន្ត្រីមុខងារនយោបាយ ដែលមានក្របខ័ណ្ឌមុខងារសាធារណៈ ដែលបានដល់អាយុចូលនិវត្តន៍ហើយ ប៉ុន្តែនៅពុំទាន់បានដាក់ឱ្យចូលនិវត្តន៍ ឬយឺតយូរក្នុងការរៀបចំបែបបទដាក់ឱ្យចូលនិវត្តន៍ គ្រប់ក្រសួង ស្ថាប័ន ត្រូវរៀបចំបែបបទដាក់ឱ្យចូលនិវត្តន៍ឱ្យអស់ យ៉ាងយូរត្រឹម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ។

**មាត្រា ៣ .-**

ការរៀបចំសោធននិវត្តន៍ សម្រាប់មន្ត្រីរាជការដូចមានចែងក្នុងមាត្រា ២ ខាងលើ ត្រូវគិតតាមកាលបរិច្ឆេទ នៃថ្ងៃខែឆ្នាំ ចេញប្រកាស ឬ អនុក្រឹត្យ ឬ ព្រះរាជក្រឹត្យ ស្តីពីការដាក់ឱ្យចូលនិវត្តន៍ ។

**មាត្រា ៤ .-**

ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១០ ទៅ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ ឱ្យបានទាន់ពេលវេលា ស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន ជាកំហិត ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**<u>កន្លែងទទួល</u> :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច ✓*
- *ឯកសារ- កាលប្បវត្តិ*

www.pheakdeylaw.com